# ល្ខោនស្បែកតូច

ស្បែកតូច ជាប្រភេទទម្រង់ល្ខោនស្បែកដូចល្ខោនស្បែកធំ និងល្ខោនស្បែកពណ៌ដែរ ដោយគ្រាន់តែមានទំហំតូចជាងគេ ហើយខុសគេត្រង់ផ្ទាំងស្បែកតូចដែលធ្វើពីស្បែកគោស្ងួត មិននៅនឹងថ្កល់ តែអាចធ្វើចលនាបានត្រង់ដៃ និងជើងអាចកម្រើកបាន និងមាត់អាចនិយាយ ឬច្រៀងបាន។ ម្យ៉ាងទៀត ល្ខោនស្បែកធំដែលជាសិល្បៈសក្ការៈសម្តែងតែរឿងដែលទាក់ទងនឹងសាសនា ជាពិសេសរឿងរាមកេរ្តិ៍ ដូច្នេះការសម្តែងតម្រូវឲ្យមានភាពជាក់លាក់ ហ្មត់ចត់ ល្ខោនស្បែកតូច មានលក្ខណៈប្រជាប្រិយសម្តែងរឿងបានច្រើនដូចជារឿងព្រេងនិទាន រឿងប្រវត្តិសាស្ត្រ និងរឿងពាក់ព័ន្ធនឹងព្រឹត្តិការណ៍ និងបច្ចុប្បន្នភាពសង្គម ក្រមិចក្រមើម កំប្លុកកំប្លែង ងាយមើល ងាយស្តាប់ និងងាយយល់។

នៅមុនសម័យប្រល័យពូជសាសន៍ខ្មែរក្រហម (១៩៧៥-១៩៧៩) យើងមានក្រុមសិល្បៈល្ខោនស្បែកតូចនៅខេត្តសៀមរាប បាត់ដំបង និងក្រុងភ្នំពេញ[១]។ ការហៅល្ខោនស្បែកតូចថា "**អាយ៉ង**" (មកពីពាក្យឥណ្ឌូណេស៊ី និងម៉ាឡេ "វ៉ាយ៉ាង" (Wayang) ឬ "ម៉ាល់យ៉ង់" (Malyang)) និង "**ណាំងកាលុង ឬណាំងតាលុង**" (មកពីពាក្យថៃសំដៅទៅលើឈ្មោះតំបន់ ផាត់ថាលុង នៃភាគខាងត្បូងនៃទីក្រុងបាងកក) ជាការភ័ន្តច្រឡំ ដែលយើងគួរកែមកហៅឱ្យត្រូវថា "**ល្ខោនស្បែកតូច ឬ ស្បែកតូច**" វិញទៅ[២]។ ម្យ៉ាងវិញទៀត បើតាមប្រសាសន៍របស់លោក ពេជ្រ ទុំក្រវិល លោកបានអះអាងថា ដែលអ្នកខ្លះនិយមហៅទម្រង់សិល្បៈនេះថា "**អាយ៉ង**" ដោយសារតុ្ក (ក្រៅពីក្រុមខេត្តសៀមរាបនិងបាត់ដំបង) ឈ្មោះ "**អាយ៉ង**" ដែលទស្សនិកជនស្រឡាញ់ ចាំជាប់នៅក្នុងចិត្ត ហើយក៏ទៅជាទម្លាប់រត់មាត់នាំគ្នាថា "តោះទៅមើលអាយ៉ង" តៗមក[៣]។ លោក ពេជ្រ ទុំក្រវិល ក៏បានមានប្រសាសន៍ជាបន្តថា នាសម័យកាលនោះ អ្នកដែលកាន់តួតុ្កនោះ គឺគាត់ឈ្មោះ "តាយ៉ង"[៤]។

---

[១] ពេជ្រ ទុំក្រវិល ២០០០: ៤១

[២] ពេជ្រ ទុំក្រវិល ២០០០: ៣៧, ៣៨, ៤១

[៣] ពេជ្រ ទុំក្រវិល ២០០០: ៤២

[៤] ពេជ្រ ទុំក្រវិល ២០០០: ៤៣

អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង

តួតុ្កក នៅក្នុងល្ខោនស្បែកតូច ដែលមានរូបរាងទាក់ទាញទស្សនិកជនគួរឱ្យចង់សើច ដោយមានគូថទយ ពោះកំប៉ោង ក្បាលត្រងោល ជាតួសំខាន់មួយនៅក្នុងទម្រង់សិល្បៈនេះ។ តាមការពិនិត្យទៅលើតួអង្គតុ្កករបស់ក្រុមសិល្បៈល្ខោនស្បែកតូចខេត្តសៀមរាបជាឧទាហរណ៍យើងឃើញថា គេច្រើនឱ្យឈ្មោះតុ្កកដែលជាតួសំណព្វចិត្តរបស់ទស្សនិកជនដូចជា "អាប៉ក់" ឬ "អាសូរ" ឬឈ្មោះផ្សេងណាមួយ[៥]។

នាសម័យមុនបច្ចុប្បន្នកាល ល្ខោនស្បែកតូចសម្តែងនៅក្នុងពិធីបុណ្យប្រពៃណីជាតិនានា មានបុណ្យចូលឆ្នាំនៅតាមទីវត្តអារាម និងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ តាំងតុ អុំទូក អកអំបុក សំពះព្រះខែ នៅទីលានខាងមុខព្រះបរមរាជវាំងនៃទីក្រុងភ្នំពេញសព្វថ្ងៃនេះ។ ក្រោយពីរបបប្រល័យពូជសាសន៍បានរលំបាត់បង់ទៅលុះមកដល់សម័យបច្ចុប្បន្ននេះ យើងឃើញនាយកដ្ឋានសិល្បៈទស្សនីយភាពដែលនៅក្រោមឱវាទនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏មានក្រុមល្ខោនស្បែកតូចមួយដែរ។

វង់ល្ខោនស្បែកតូច មានអ្នកពោលឆ្លាតវាងវៃ ប្រកបដោយសំនួនវោហារឥតព្រាងទុក មានគំនិតកំប្លុកកំប្លែង អាចទាក់ទាញអារម្មណ៍ទស្សនិកជនឲ្យសើចសប្បាយរីករាយជាមួយនឹងការសម្តែងបាន។ យោងតាមឯកសារស្រាវជ្រាវ យើងឃើញថាវង់តន្ត្រីកំដរល្ខោនស្បែកតូច មិនមានភាពដូចគ្នាទាំងអស់នោះទេ ពោលគឺ ទស្សនីយភាពល្ខោនស្បែកតូចនៅខេត្តសៀមរាប និងក្រុងភ្នំពេញ គឺកំដរដោយវង់តន្ត្រីពិណពាទ្យវង់តូចដែលមានឧបករណ៍រនាតឯក១ ស្រឡៃធំ១ គងធំ១ សម្ភោរ១ និងស្គរធំ១គូ។ ឯល្ខោនស្បែកតូចខេត្តបាត់ដំបង គឺកំដរដោយវង់តន្ត្រី ដែលមានឧបករណ៍ស្រឡៃតូច១ គងដោះឬគងម៉ង់១ ស្គរដៃ១គូ ស្គរតូចរាងដូចស្គរធំពិណពាទ្យ១ និងពេលខ្លះមានទាំងកំណាត់ដើមឫស្សីមានគ្រាប់ខាងក្នុង១ផង[៦]។

---

[៥] ពេជ្រ ទុំក្រវិល ២០០០: ៤១

[៦] ពេជ្រ ទុំក្រវិល ២០០០: ១០៩-១១០

អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង

## ឯកសារយោង

ពេជ្រ, ទុំក្រវិល
២០០០. *ស្បែកពណ៌និងស្បែកតូច*. ភ្នំពេញៈ មូលនិធិ តូយ៉ូតា។

ពេជ្រ ទុំក្រវិល
២០០៣. *ទស្សនីយភាពខ្មែរ*. ភ្នំពេញៈ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។



